សម្រាប់ការចុះផ្សាយបន្ទាន់ ៖ ថ្ងៃសុក្រទី ១៩ មេសា ២០២០
លេខទំនាក់ទំនងសាលាក្រុង 781-286-8111

# សារលិខិតរបស់សាលាក្រុងជុំវិញ COVID-19៖ ថ្ងៃទី ១៩ មេសា ២០២០

## *រកឃើញចំនួនអ្នកឆ្លងសរុប ៧០០ នាក់ បន្ទាប់ពីការធ្វើតេស្តលក្ខណៈទ្រង់ទ្រាយធំ ឡានរបស់សាលាក្រុងនឹងចេញប្រកាសផ្សាយព័ត៌មានផ្សេងៗ ដើម្បីរំលឹកឲ្យអ្នកទៅលេងសមុទ្រមកស្នាក់នៅផ្ទះ និងអនុវត្តការរក្សាគម្លាតសង្គម*

ថ្ងៃទី ១៩ មេសា ២០២០២ – ក្រុមឆ្លើយតបរហ័សប្រចាំក្រុង Revere នៅតែបន្តការងារយ៉ាងសកម្ម ដើម្បីកាត់បន្ថយល្បឿននៃការឆ្លង និងការរាលដាលនៃជំងឺ COVID-19។ ហើយបានរៀបចំវិធានការរួចជាស្រេចដើម្បីទប់ទល់នឹងការឆ្លងនានា។ នៅថ្ងៃនេះ នាយកដ្ឋានសុខាភិបាលរបស់រដ្ឋ Massachusetts បានផ្តល់ដំណឹងមកកាន់ក្រុមសុខាភិបាលប្រចាំក្រុង Revere ថា បានរកឃើញអ្នកឆ្លងមេរោគ COVID-19 ចំនួន ៦៩៤ នាក់ នៅក្នុងក្រុង Revere ខណៈ ១១៥ ករណីត្រូវបានរកឃើញក្នុងសប្តាហ៍ថ្មីនេះ។

‟ពួកយើងបានឈានមកដល់ចំណុចដ៏ខ្ពស់មួយហើយ ដោយមេរោគនេះបានរីករាលដាលខ្លាំងមែនទែនក្នុងក្រុងរបស់យើង។ យើងគិតទុកជាមុនថាចំនួនអ្នកឆ្លងអាចនឹងកើនឡើងច្រើនទៀតនៅប៉ុន្មានថ្ងៃខាងមុខ។ ទិន្នន័យថ្មីៗនេះបានបញ្ជាក់ថា មានមនុស្សជាច្រើនធ្លាប់បានប៉ះពាល់ និងមានទំនាក់ទំនងជាមួយជាអ្នកដែលបានឆ្លងទាំងនោះ។″ លោកអភិបាល Arrigo និយាយ។ ‟នេះគួសបញ្ជាក់ថា អ្នកទាំងអស់គ្នាពិតជាមានកាតព្វកិច្ចសំខាន់ក្នុងការកាត់បន្ថយល្បឿននៃការឆ្លងនេះ។ បើទោះបីជាអ្នកគិតថាខ្លួនមានសុខភាពល្អក៏ដោយ អ្នកក៏អាចមានឱកាសធ្វើឲ្យមេរោគរាលដាលបានដែរ។ សូមបន្តស្នាក់នៅផ្ទះ និងការពារខ្លួនឲ្យបានល្អិតល្អន់ពេលដែលត្រូវចេញពីផ្ទះម្តងៗ"។

១១៥ ករណីដែលត្រូវបានរកឃើញក្នុងពេលថ្មីៗនេះ ភាគច្រើនត្រូវបានទទួលបានការថែទាំពីមណ្ឌលថែទាំឯកជន។ សមត្ថកិច្ចថ្នាក់ជាតិត្រៀមខ្លួនជាស្រេច ដើម្បីសម្របសម្រួលការធ្វើតេស្តលើប្រជាជនទាំងអស់នៅក្នុងក្រុង។ គិតត្រឹមល្ងាច

ថ្ងៃអាទិត្យនេះ ជាងពាក់កណ្តាលនៃប្រជាជនដែលបានធ្វើតេស្ត ត្រូវបានរកឃើញថាមានផ្ទុកមេរោគ COVID–19។ សាលាក្រុង Revere បានធ្វើការទាក់ទងជាញឹកញាប់ជាមួយក្រុមអ្នកផ្គត់ផ្គង់សេវាថែទាំ និងបានបញ្ចេញការណែនាំទៅកាន់អ្នកដែលបម្រើសេវាថែទាំសុខភាពមនុស្សចាស់ជរាទាំងអស់តាំងពីថ្ងៃទី ២៦ មិនា ២០២០ មកម្ល៉េះ។ ប្រការដែលត្រូវធ្វើមានដូចជា៖

- ត្រូវការពារភ្នែក នៅពេលដែលអ្នកចូលទៅមើលថែទាំអ្នកជំងឺ
- សម្អាត និងលាងគ្រប់ទីតាំង រាល់ពេលផ្លាស់ប្តូរវេន និងបន្ថែមម៉ោងសម្រាប់ការសម្អាត
- បន្ថែមបុគ្គលិកសម្រាប់អ្នកមានជំងឺវង្វេង
- ត្រួតពិនិត្យមើលអាការៈ ឬរោគសញ្ញារបស់ពួកគេឲ្យបាន ៣ ដងក្នុងមួយថ្ងៃ
- ត្រូវពាក់ម៉ាស់គ្រប់ពេល បន្ទាប់ពីចូលពីផ្ទះ ឬអាគារ ឬសាលាប្រជុំណាមួយ។

ឡានរបស់សាលាក្រុងនឹងធ្វើយុទ្ធនាការប្រកាសម្តងទៀតនៅឆ្នេរតាម Revere Beach ដើម្បីធ្វើការផ្សព្វផ្សាយជាលក្ខណៈច្រើនភាសា ក្នុងគោលបំណងក្រើនរំលឹកដល់អ្នកទៅលេងសមុទ្រទាំងអស់ ឲ្យមកស្នាក់នៅផ្ទះ និងអនុវត្តវិធានការរក្សាគម្លាតសង្គម៕

###